ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម
BSDA
BUDDHISM FOR SOCIAL DEVELOPMENT ACTION ORGANIZATION

# គោលនយោបាយការពារកុមារ និងមនុស្សធំពេញវ័យ

# Child Protection and Vulnerable Adults Policy

2024

កែប្រែលើកទី៦

# មាតិកា

Content

**ទំព័រ**

Page


អំពីអង្គការ BSDA.......................................................................................................៣

ប្រការ១.គោលបំណង.......................................................................................................៥

ប្រការ២.និយមន័យ.......................................................................................................៥

ប្រការ៣.សុវត្ថិភាព កិច្ចការពារកុមារ និងមនុស្សធំពេញវ័យ.....................................................៦

ប្រការ៤.ការជ្រើសរើសបុគ្គលិកសម្រាប់មុខដំណែងដែលធ្វើការ...................................................៦

ប្រការ៥.ការប្រាស្រ័យទាក់ទងអំពីកុមារ និងមនុស្សធំពេញវ័យ...................................................៧

ប្រការ៦.បណ្ដាញ និងការគាំទ្រ.......................................................................................៨

ប្រការ៧.ក្រមសីលធម៌ចំពោះការការពារកុមារនិងមនុស្សធំពេញវ័យ............................................៨

ប្រការ៨.ដំណើរការអនុវត្តនៅក្នុងអង្គការក្នុងករណីសង្ស័យអំពីការរំលោភបំពាន...............................៩

# សេចក្តីផ្តើម

**សាវតាររបស់** BSDA

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីការអភិវឌ្ឍសង្គម(BSDA) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០៥ ដោយព្រះសង្ឃ ៧អង្គ នៅវត្តនគរបាជ័យ។ក្រសួងមហាផ្ទៃបានទទួលស្គាល់BSDAតាមរយៈលេខ១៦២ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ ។ BSDAមិនធ្វើការបម្រើឱ្យគណបក្សនយោបាយណាឬក៏ផ្សព្វផ្សាយពីសាសនារបស់សមាជិកខ្លួនឡើយ។

អង្គការ BSDA គឺផ្តោតតែលើការអភិវឌ្ឍសង្គម និងជួយប្រជាជនក្រីក្របំផុតដែលកំពុងរស់ក្នុងសហគមន៍ក្រីក្រ។

**អត្តសញ្ញាណ**

ស.ព.អ.ស ជាអង្គការសហគមន៍បានបង្កើតឡើងនៅលើ គោលការណ៍ព្រះពុទ្ធសាសនានៃធម៌មេត្តា ដើម្បីផ្តល់អំណាចដល់ប្រជាជនដែលងាយរងគ្រោះ និងដើម្បីលើកកម្ពស់ការចូលរួមទំនាក់ទំនងល្អក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីរួមចំណែកលុបបំបាត់នៃភាពរងគ្រោះឬក្រីក្រ។

**គុណតម្លៃ**

ជាឫសគល់ក្នុងការបង្រៀនរបស់ព្រះពុទ្ធដោយអនុវត្តធម៌មេត្តាBSDA បានប្រកាន់ខ្ជាប់និងលើក កម្ពស់គុណតម្លៃរបស់ខ្លួនដូចខាងក្រោម:

- **បម្រើអ្នកក្រីក្រ៖**កែលម្អជី វភាពរស់នៅរបស់គ្រួសារអ្នកក្រីក្រ។
- **សាមគ្គីភាព៖**កសាង ជំនឿជាក់ ភាពស្មោះត្រង់ និងការគោរពគ្នាដូចជាគ្រួសារ។
- **លទ្ធិប្រជាធិបតេយ្យ៖**លើកកំពស់សំលេងរួមពីសហគមន៍ អ្នកពាក់ព័ន្ធ និងបុគ្គលិក គ្រប់លំដាប់ថ្នាក់នៅក្នុងដំណើរការធ្វើការសេចក្តីសម្រេចអ្វីមួយ។
- **នវានុវត្តន៍:** ការផ្តល់នូវឱកាសតែមួយគត់សម្រាប់ប្រជាពលរដ្ឋ ក្នុងការដោះស្រាយបញ្ហារបស់ពួកគេ តាមរយៈព័ត៌មានបច្ចេកវិទ្យាគមនាគមន៍ (ICT) និងការគិតត្រិះរិះពិចារណា។
- **សុចរិតភាព និងគណនេយ្យភាព៖**នៅក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ជំនួយ! ត្រូវបានទទួលខុសត្រូវខ្ពស់ និងមានតម្លាភាពដល់សហគមន៍ ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធ។

**ទស្សនៈវិស័យ**

អង្គការ ស.ព.អ.ស ចង់ឃើញសង្គមដែលប្រជាពលរដ្ឋរស់នៅដោយឯករាជ្យនិងអាចចិញ្ចឹមជីវិតបានដោយខ្លួនឯង។

**បេសកកម្ម**

ស.ព.អ.ស គឺដើម្បីជំរុញ និងលើកកម្ពស់ជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ ដែលងាយរងគ្រោះ ជាពិសេសស្ត្រីកុមារ និងយុវជន តាមរយៈវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សហគ្រាសសង្គម អភិបាលកិច្ចល្អ និងការផ្តួចផ្តើមអភិវឌ្ឍន៍ជីវភាពរស់នៅ និងកម្មវិធីនវានុវត្តន៍ជាដៃគូជាមួយអ្នកផ្សេងៗ។

## ទិសដៅជាយុទ្ធសាស្ត្រ

- អនុវត្តន៍កម្មវិធីចម្រុះ និងប្រកបដោយភាពច្នៃប្រឌិត
- ការបង្កើតទំនាក់ទំនងរឹងមាំ
- ការប្រកបមុខរបររស់នៅប្រកបដោយនិរន្តរភាព
- ការបង្កើតយុទ្ធសាស្ត្រគៀគរថវិកាប្រកបដោយនិរន្តរភាព
- បន្តការរៀន និងរីកចម្រើន
- ការកសាងសមត្ថភាពបុគ្គលិក

## គោលបំណង

ដើម្បីធានានិរន្តរភាព គណនេយ្យភាពតម្លាភាព សុវត្ថិភាពបុគ្គលិកនិងភាពត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## វិសាលភាព

គោលនយោបាយនេះអនុវត្តទៅលើថ្នាក់ដឹកនាំនិងបុគ្គលិករបស់អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គមទូទាំងប្រទេសកម្ពុជា។

**ប្រការ១.គោលបំណង**

កុមារបង្កើតជាក្រុមមនុស្សពិសេសមួយ ដែលប្រឈមនឹងឧបសគ្គជាច្រើន ដោយហេតុតែបញ្ហាសង្គម ដូចជាការឆ្លងរាលដាលនៃមេរោគ/ជំងឺអេដស៍ និងការខ្វះខាតការទទួលស្គាល់សិទ្ធិកុមារ។ ការបាត់បង់ការថែរក្សារបស់ឪពុកម្តាយ ឬការរស់នៅជាមួយឪពុកម្តាយ ឬអ្នកផ្តល់ការថែរក្សាដែលឆ្លងរោគ បង្កើនភាពងាយរងគ្រោះរបស់កុមារ។ កុមារអាចពាក់ព័ន្ធជាមួយសកម្មភាពដូចជាការជួញដូរផ្លូវភេទ និងពលកម្មកុមារឬបង្ខំឱ្យធ្វើសកម្មភាពខុសច្បាប់ដូចជាការជួញដូរថ្នាំញៀន។ មនុស្សដែលមានអំណាចឬ ដំណែងមានឥទ្ធិពលក្នុងសហគមន៍ រួមបញ្ចូលទាំងអ្នកផ្តល់ជំនួយ និងអ្នកធ្វើការនៅក្នុងអង្គការក្រៅរដ្ឋាភិបាល អាចរំលោភបំពាននិងកេងចំណេញពីកុមារ។ នេះនាំឱ្យមានការអំពាវនាវរកសកម្មភាពការពារកុមារ ពីការរំលោភបំពាន និងការកេងប្រវ័ញ្ច។

គ្រប់បុគ្គលិក និងអ្នកពាក់ព័ន្ធទាំងអស់របស់អង្គការ ត្រូវមានទំនួលខុសត្រូវក្នុងនាមជាអ្នកការពារកុមារ និងអ្នកទទួលផលជាមនុស្សធំពេញវ័យ តាមរយៈការទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងបង្ការចំពោះគ្រោះថ្នាក់ទាំងឡាយណា ដែលកើតចេញដោយចេតនា ឬអចេតនា ចំពោះគ្រប់បុគ្គលទាំងអស់ដែលអង្គការកំពុងបម្រើ។គ្រប់បុគ្គលិកនិងអ្នកពាក់ព័ន្ធទាំងអស់របស់អង្គការត្រូវគោរពតាមក្រមចរិយាធម៌ ចំពោះរាល់សកម្មភាពរបស់ពួកគេ ដែលពាក់ព័ន្ធជាមួយអង្គការ និងរាល់សកម្មភាពជាមួយកុមារ និងមនុស្សពេញវ័យដែលជាអ្នកទទួលផល។ យោងតាមមបទដ្ឋាននៃការការពារកុមារអង្គការបានប្រើប្រាស់ពាក្យ "ក្រុមអ្នកទទួលផល"ក្នុងន័យទូលាយ ដោយមិនសំដៅតែអ្នកទទួលផលជាក់លាក់ ពីគម្រោងណាមួយជាពិសេសនោះទេ ប៉ុន្តែពាក្យនេះសំដៅទៅលើទាំងកុមារ និងមនុស្សធំពេញវ័យទាំងអស់ដែលស្ថិតនៅក្នុងតំបន់ប្រតិបត្តិការរបស់អង្គការទាំងមូល។

**ប្រការ២.និយមន័យ**

កុមារ មានន័យថាជាមនុស្សទាំងឡាយណាដែលមានអាយុតិចជាង ១៨ឆ្នាំ។

ការរំលោភបំពានលើកុមារ **និងមនុស្សធំពេញវ័យ** មានន័យថា ជាការរំលោភបំពានផ្លូវភេទ ឬរាងកាយ ឬ ធ្វើបាបផ្លូវចិត្តដោយចេតនាចំពោះកុមារ។

គោលនយោបាយការពារកុមារ និងមនុស្សពេញវ័យ គឺសំដៅទៅលើ ការបង្ការ ការរាយការណ៍ និងការឆ្លើយតប ចំពោះគ្រោះថ្នាក់ ឬការរំលោភបំពានផ្សេងៗ ចំពោះកុមារ និងមនុស្សធំពេញវ័យ ដែលអាចប្រព្រឹត្តដោយបុគ្គលិកអង្គការស្តារកម្ពុជា ឬអ្នកពាក់ព័ន្ធ។

ការរំលោភបំពានកុមារ និងមនុស្សធំពេញវ័យអាចជាការរំលោភបំពានផ្នែកផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ការខ្វះការយកចិត្តទុកដាក់ និងពលកម្មកុមារះ

- **ការរំលោភបំពានផ្លូវកាយះ**

ការរំលោភបំពានផ្លូវកាយកើតឡើង នៅពេលមនុស្សមានបំណងបង្ករបួស ឬគំរាមបង្ករបួសដល់កុមារ ឬមនុស្សវ័យក្មេង។ នេះមានមានទម្រង់ជាការទះ កាវាយដំ ការបោះ ការទាត់ការដុតការរុញឬការកញ្ឆក់។របួសស្នាមអាចមានទម្រង់ជាស្នាមជាំមុតរលាក ឬបាក់។

• **ការរំលោភបំពានផ្លូវចិត្ត៖**

ការរំលោភបំពានផ្លូវចិត្តគឺជាការវាយប្រហាររ៉ាំរ៉ៃចំពោះការឱ្យតម្លៃខ្លួនរបស់កុមារឬមនុស្សវ័យក្មេង ។ វាអាចមានទម្រង់ជាការហៅឈ្មោះ ការគំរាម ការចំអក ការសម្លុត ឬការដាក់កុមារ ឬមនុស្សវ័យក្មេងឱ្យនៅដាច់ពីគេ។

• **ការខ្វះការយកចិត្តទុកដាក់៖**

ការខ្វះការយកចិត្តទុកដាក់ គឺជាការបរាជ័យក្នុងការផ្តល់ ឱ្យកុមារនូវតម្រូវការមូលដ្ឋានសម្រាប់ជីវិត (នៅពេលណាដែលតម្រូវការនេះមាន) ដូចជាអាហារ សម្លៀកបំពាក់ ជម្រក និងការគ្រប់គ្រងចំពោះផ្នែកដែលសុខភាព និងការអភិវឌ្ឍរបស់កុមារទទួលការប្រឈម។

• **ការរំលោភបំពានផ្លូវភេទ**

ការរំលោភបំពានផ្លូវភេទគឺនៅពេលដែលកុមារ ឬមនុស្សវ័យក្មេងត្រូវបានប្រើប្រាស់ដោយមនុស្សធំ ឬក្មេងធំជាង ក្មេងជំទង់ ឬមនុស្សពេញវ័យសម្រាប់ជាការភ្លោច ការបំពេញអារម្មណ៍ផ្លូវភេទរបស់គាត់/នាង ឬដើម្បីជាផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច។

• **ពលកម្មលើកុមារ**

ការរំលោភបំពាន ដោយកេងប្រវ័ញ្ចទៅលើកុមារ ធ្វើឲ្យកុមារបាត់បង់ស្មារតី បាត់បង់ពេលវេលារៀនសូត្រ និងមានផលប៉ះពាល់ដល់កុមារយ៉ាងធ្ងន់ធ្ងរ នាពេលអនាគត។

គោលនយោបាយការពារកុមារ គឺជាសេចក្តីបញ្ជាក់ពីគោលបំណង នៃការប្តេជ្ញាចិត្តដើម្បីរក្សាការពារកុមារពីការធ្វើទុក្ខទោស និងធ្វើឱ្យច្បាស់ចំពោះអ្វីទាំងអស់ដែលចាំបាច់ទាក់ទង នឹងការការពារកុមារ។ វាជួយបង្កើតបរិយាកាសវិជ្ជមាន និងសុវត្ថិភាពសម្រាប់កុមារ និងដើម្បីបង្ហាញថា អង្គការកំពុងបំពេញភារកិច្ចរបស់ខ្លួនក្នុងការថែរក្សាយ៉ាងហ្មត់ចត់។

**ប្រការ៣.សុវត្ថិភាព កិច្ចការពារកុមារ និងមនុស្សធំពេញវ័យ**

គោលនយោបាយនេះមិនត្រឹមតែផ្តោតសំខាន់ទៅលើកុមារក្រោមអាយុ១៨ឆ្នាំប៉ុណ្ណោះនោះទេ អង្គការបានផ្តល់ការយកចិត្តទុកដាក់ផងដែរចំពោះមនុស្សធំពេញវ័យ ដែលចំណុចនេះសំដៅទៅលើការបង្ការ ការរាយការណ៍និងការឆ្លើយតប ចំពោះគ្រោះថ្នាក់ ឬការបំពានផ្សេងៗទៅកាន់កុមារ និងមនុស្សធំពេញវ័យដែលប្រព្រឹត្តដោយបុគ្គលិករបស់អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម ឬអ្នកពាក់ព័ន្ធ។

គ្រប់បុគ្គលិក ថ្នាក់ដឹកនាំ និងភាគីពាក់ព័ន្ធរបស់អង្គការត្រូវប្រកាន់យ៉ាងខ្ជាប់ខ្ជួនចំពោះសុវត្ថិភាព និងកិច្ចការពារកុមារ និងមនុស្សធំពេញវ័យ។

**ប្រការ៤.ការជ្រើសរើសបុគ្គលិកសម្រាប់មុខដំណែងដែលធ្វើការជាមួយកុមារ និងមនុស្សធំពេញវ័យ**

• និយោជិតដែលមានសក្តានុពល និងនិយោជិតបច្ចុប្បន្នដែលធ្វើការទាក់ទងដោយផ្ទាល់ ឬជាប្រចាំជាមួយកុមារ នឹងត្រូវទទួលដំណើរការពិនិត្យជ្រើសរើស ដើម្បីត្រួតពិនិត្យមើលសម្រាប់ការរំលោភបំពានកុមារកំណត់ត្រាបទល្មើសដែលពាក់ព័ន្ធ។

• ប្រសិនបើអាច ការពិនិត្យកំណត់ត្រាបទល្មើសអាចត្រូវស្នើសុំ ប្រសិនបើមានការសង្ស័យ ឬសមាជិកបុគ្គលិកប្តូរទៅកាន់ផ្នែកថ្មីដែលពាក់ព័ន្ធជាមួយកុមារ។ក្នុងករណីនេះ BSDAនឹងស្នើសុំនិយោជិត ដែលមានសក្តានុពលចុះហត្ថលេខាលើទម្រង់ ផ្តល់សិទ្ធិពិនិត្យកំណត់ត្រាបទល្មើសរបស់គាត់/នាង។

• អ្នកស្ម័គ្រចិត្ត និងអ្នកហ្វឹកហាត់ការងារនឹងត្រូវប្រឈម នឹងការពិនិត្យមើលកំណត់ត្រាបទល្មើស ដោយភ្នាក់ងារ ឬអង្គការរបស់ពួកគេ ប្រសិនបើពួកគេធ្វើការងារ ដែលទាក់ទងជាមួយកុមារជាប្រចាំ។ BSDA នឹងបញ្ជាក់ជាមួយភ្នាក់ងារដែលថាកិច្ចការនេះបានធ្វើរួច។

• ក្នុងកំឡុងពេលសម្ភាសជ្រើសរើសបេក្ខជន ក្រុមអ្នកសម្ភាសន៍នឹង កំណត់ការខ្វះខាតនៅក្នុងប្រវត្តិរូបការងាររបស់បេក្ខជន និងបញ្ជាក់ពីមូលហេតុសម្រាប់បញ្ហានេះឱ្យពេញចិត្ត។ ប្រសិនបើក្រុមមិនពេញចិត្តចំពោះការពន្យល់ សម្រាប់ការខ្វះចន្លោះក្នុងកំណត់ត្រាជួល នេះនឹងជាមូលហេតុគ្រប់គ្រាន់ក្នុងការបដិសេធបេក្ខភាពក្នុងដំណាក់កាលនៃការជ្រើសរើសនោះ។

• បេក្ខជនដែល នឹងធ្វើការជាមួយកុមារនឹងត្រូវបានសាក សួរសំណួរជាក់លាក់មួយចំនួនក្នុងកំឡុងពេលសម្ភាស៍ដើម្បីអង្កេត ពីអត្តចរិតរបស់របស់បេក្ខជន បទពិសោធន៍ និងវិធីសាស្រ្តក្នុងការធ្វើការជាមួយកុមារដែលស្មើគ្នាទៅនឹងមុខដំណែងដែលពួកគេបានដាក់ស្នើសុំ។

• នៅពេលដែលបេក្ខជន ដែលត្រូវបានពិចារណាប្រគល់ មុខដំណែងបានបញ្ចេញឱ្យដឹងពីការផ្តន្ទាទោសបទល្មើសក្នុងកំឡុងពេលសម្ភាស គួរមានការសម្ភាសតាមដានមួយទៀតដើម្បីដោះស្រាយចំពោះសំណួរជាក់លាក់ដើម្បីទទួលបានព័ត៌មានអំពីប្រវត្តិរូប និងព្រឹត្តិការណ៍។ នៅពេលដែលបេក្ខជនបានដឹងថាត្រូវប្រឈមមុខជាមួយដំណើរការដាក់វិន័យជាមួយនិយោជកមុនព្រឹត្តិការណ៍នេះ គួរត្រូវបានស្វែងយល់ជាមួយគាត់/នាង និង និយោជកមុន។

• បេក្ខជនមិនគួរត្រូវបានបដិសេធទាំងស្រុង ដោយផ្អែកលើការផ្តន្ទាទោសបទល្មើស ឬកំណត់ត្រាវិន័យ ដោយគ្មានការពិនិត្យចំពោះព្រឹត្តិកាណ៍នោះទេ។

**ប្រការ៥.ការប្រាស្រ័យទាក់ទងអំពីកុមារ និងមនុស្សធំពេញវ័យ**

នៅក្នុងយុទ្ធសាស្រ្តស្វែងរកជំនួយ និងទំនាក់ទំនង បុគ្គលិករបស់ BSDA អាចប្រើប្រាស់រូបភាព និងកំណត់ត្រារបស់កុមារ និងអត្ថបទសិក្សា។ បុគ្គលិកត្រូវមានទំនួលខុសត្រូវចំពោះកុមារដែលត្រូវបានយករូបភាព និងគួរតែធានាថា កុមារត្រូវបានប្រព្រឹត្តិដោយសេចក្តីថ្លៃថ្នូររបស់មនុស្សជាមួយសិទ្ធិ ដោយជៀសវាងចំណុចខាងក្រោម៖

- ការតំណាងមិនត្រឹមត្រូវអំពីកុមារ តាមរយៈពាក្យ និងរូបភាព។
- ការផ្សព្វផ្សាយដែលនាំឱ្យអាម៉ាស់ អាប់កិត្តិយស ឬបោកបញ្ឆោតកុមារ។
- ការថតរូប ឬយកពាក្យសម្តីពីកុមារដោយគ្មានការអនុញ្ញាត។
- ការពណ៌នាកុមារក្នុងលក្ខណៈបង្កឱ្យមានចំណាង់ផ្លូវភេទ។
- ការប្រាស្រ័យទាក់ទងតាមអនឡាញ ឬបណ្តាញសង្គមផ្សេងៗ ត្រូវប្រុងប្រយ័ត្នខ្ពស់ ជាហេតុនាំឱ្យមានផលមិនល្អដល់កុមារ និងមនុស្សធំពេញវ័យ។

សេចក្តីអនុញ្ញាតពីកុមារ និងឪពុកម្តាយរបស់គាត់/នាង ឬអាណាព្យាបាល គួរត្រូវបានធ្វើឡើងមុនពេលមានការថតសម្លេង ថតរូប ឬរូបភាពត្រូវយកពីគាត់/នាង ហើយគោលបំណងក្នុងការប្រើប្រាស់ក៏ត្រូវបានពន្យល់ផងដែរ។BSDAណែនាំទម្រង់មួយសម្រាប់នាយកសាលាចុះសហត្ថលេខាដើម្បីសេចក្តីអនុញ្ញាត

រៀងរាល់ឆ្នាំដើម្បីយក និងប្រើប្រាស់រូបភាពរបស់សាលា និងក្រុមកុមារ (៣ ឬច្រើនជាងនេះ)។ នៅពេលណាដែលអាចធ្វើបានកុមារនិងគ្រួសារគួរត្រូវបានបង្ហាញពីផលិតផលចុងក្រោយមុនពេលធ្វើការបោះពុម្ភ។

(មើលឧបសម្ព័ន្ធ១ សម្រាប់ទម្រង់សេចក្តីអនុញ្ញាតរបស់ឪពុកម្តាយ ឬនាយកសាលា)

**ប្រការ៦.បណ្តាញ និងការគាំទ្រ**

• វាគួរតែមានដំណើរការ កិច្ចខិតខំដើម្បីកំណត់ និង ចងក្រងជាឯកសារ ចំពោះការអនុវត្តល្អបំផុតចំពោះការការពារកុមារ។

• ក្រុមគម្រោង MKK នឹងសម្របសម្រួលដំណើរការលើកកម្ពស់ការយល់ដឹងពីការការពារកុមារការលើកឡើងក្នុងចំណោមបុគ្គលិកនិងដៃគូ។ អង្គការលើកទឹកចិត្តចំពោះការចូលរួមរបស់សមាជិកបុគ្គលិកក្នុងការគាំទ្រសិទ្ធិកុមារនៅគ្រប់កម្រិត។

**ប្រការ៧.ក្រមសីលធម៌ចំពោះការ ការពារកុមារ និងមនុស្សធំពេញវ័យ**

BSDA បានបង្កើតក្រមសីលធមិចំពោះការការពារកុមារដែលបុគ្គលិកនឹងត្រូវបានសុំឱ្យចុះហត្ថលេខានៅពេលចាប់ផ្តើមការងារនៅក្នុងអង្គការ។ ការណែនាំឱ្យយល់ពីខ្លឹមសាររបស់ឯកសារ នឹងត្រូវផ្តល់ជូនដើម្បីធ្វើឱ្យប្រាកដថា បុគ្គលិកថ្មីយល់វាយ៉ាងច្បាស់។

(មើលឧបសម្ព័ន្ធ ២ សម្រាប់ក្រមសីលធមិស្តីពីកិច្ចការពារកុមារ និងមនុស្សធំពេញវ័យ)

**ក្រមសីលធម៌រួមមាន៖**

- អាកប្បកិរិយាដែលអនុញ្ញាត្តខណៈពេលធ្វើការជាមួយកុមារ
- របៀបក្នុងការគ្រប់គ្រងព័ត៌មានអំពីកុមារ (រូបថត/វីដេអូ/ឌីវីឌី/...)
- អាកប្បកិរិយាហាមឃាត់ដែលអាចប៉ះពាល់ដល់កុមារ ដូចជារូបភាពរបស់ BSDA

**ប្រការ៨.ដំណើរការអនុវត្តនៅក្នុងអង្គការក្នុងករណីសង្ស័យអំពីការរំលោភបំពាន**

BSDAបានកំណត់ដំណើរការដូចខាងក្រោម ក្នុងករណីដែលបុគ្គលិកទទួលព័ត៌មានអំពីការរំលោភបំពានដែលអាចកើតមាន៖

**ជំហានទី១៖** ជូនដំណឹងដល់អ្នកគ្រប់គ្រងផ្ទាល់

**ជំហានទី២៖** អ្នកគ្រប់គ្រងផ្ទាល់ត្រូវទទួលខុសត្រូវទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន។ ក្នុងករណីដែលមិនអាចទាក់ទងអ្នកគ្រប់គ្រងផ្ទាល់បាន បុគ្គលិកគួរចាប់ផ្តើមជូនដំណឹង ដល់អាជ្ញាធរមានសមត្ថកិច្ច។ បន្ទាប់មក បុគ្គលិកត្រូវទទួលខុសត្រូវក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកគ្រប់គ្រងផ្ទាល់ យ៉ាងឆាប់បំផុតតាមតែអាចធ្វើបាន។

**ជំហានទី៣៖** អ្នកគ្រប់គ្រងផ្ទាល់ ឬបុគ្គលិកផ្តល់ព័ត៌មានដល់អង្គការពាក់ព័ន្ធ ( ឧ. លីកាដូ/ ILO/ ADHOC)ដែលធ្វើការលើផ្នែកនេះដូច្នេះពួកគេអាចតាមដានករណីនេះជាមួយអាជ្ញាធរមូលដ្ឋានដែលទទួលបន្ទុក។

**ជំហានទី៤៖**ផ្តល់ព័ត៌មានដល់មន្ទីរដែលពាក់ព័ន្ធ

រាល់ព័ត៌មានទាំងអស់ ដែលអាចចាត់ទុកជាការរំលោភបំពាន នឹងត្រូវរក្សាការសម្ងាត់។ របៀបក្នុងការទំនាក់ទំនងរវាង BSDA និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ និងអង្គការពាក់ព័ន្ធត្រូវគោរពការរក្សាការសម្ងាត់ និងសិទ្ធិរបស់កុមារ និងមនុស្សធំពេញវ័យជាអាទិភាព។

ខ្លឹមសារ ឬបទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងគោលនយោបាយខាងលើត្រូវទុកជានិរាករណ៍។

ថ្ងៃពុធ ៨រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
កំពង់ចាម ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០២៤

**ហត្ថលេខា**

**ឃឺត ព្រីដេនប៊ឺក**
Kurt Bredenberg
**ប្រធានក្រុមប្រឹក្សាភិបាល**
Chairman of Board of Director

**ហត្ថលេខា**

**ឈុន ស្រស់**
Chhon Srors
**នាយិកាប្រតិបត្តិ**
Executive Director